អគ្គលេខាធិការដ្ឋាន
មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ

អត្ថបទខ្លីៗអំពីបច្ចេកវិទ្យាហិរញ្ញវត្ថុ

លេខ ០០១ ខែធ្នូ ឆ្នាំ២០២៣

# ទស្សនាទាន
# ស្ថាបនូបនីយកម្មសេដ្ឋកិច្ចឌីជីថលកម្ពុជា

ដោយ ខេន ចន្ថា* និង សូ សុភា**

## ខ្លឹមសារសង្ខេប

សេដ្ឋកិច្ចឌីជីថលកម្ពុជា គឺជាម៉ូដែលថ្មីនៃកំណើនសេដ្ឋកិច្ចទីផ្សារ។ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យកម្ពុជារយៈពេលវែង, រាជរដ្ឋាភិបាលបានធ្វើស្ថាបនូបនីយកម្មសេដ្ឋកិច្ចឌីជីថលកម្ពុជា អនុលោមតាមបទពិសោធ, ឧត្តមានុវត្តន៍ និងនិន្នាការស្ថាបនូបនីយកម្មសេដ្ឋកិច្ចឌីជីថលក្នុងបរិការណ៍តំបន់និងសកល ដែលមានសមានគតិភាពជាមួយនឹងបរិការណ៍កម្ពុជា។ ស្ថាបនូបនីយកម្មសេដ្ឋកិច្ចឌីជីថលកម្ពុជា ស្ថិតនៅលើម៉ាគាគោលនយោបាយនិងយុទ្ធសាស្ត្រដ៏ត្រឹមត្រូវនៃប្រមុខរាជរដ្ឋាភិបាល ដែលបានយកចិត្តទុកដាក់ខ្ពស់លើការបង្កើតស្ថាប័នមានសមត្ថកិច្ចដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល, ស្ថាប័នដឹកនាំសម្របសម្រួលនិងជំរុញ និងស្ថាប័នចូលរួមគាំទ្រនានា។ ស្ថាបនូបនីយកម្មសេដ្ឋកិច្ចឌីជីថលកម្ពុជា នៅមានចំណុចខ្វះខាតមួយចំនួនដែលតម្រូវឱ្យមានការដាក់ចេញនិងការអនុវត្តនូវទិសដៅយុទ្ធសាស្ត្រសុរ្ទ៉ឡិកម្ម ប្រកបដោយប្រសិទ្ធភាពនិងសក្តិសិទ្ធិភាព ក្នុងស្មារតីនៃការកែទម្រង់និងការពង្រឹងអភិបាលកិច្ចស្ថាប័ន ដើម្បីបម្រើឧត្តមប្រយោជន៍ជាតិនិងប្រជាជនជាធំ អនុលោមតាមគោលនយោបាយ, យុទ្ធសាស្ត្រ, ផែនការអភិវឌ្ឍ, ផែនទីមគ្គុទេសក៍, ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

@fintechportalfsa

អានបន្ត...

# មាតិកានុក្រម


**សេចក្តីផ្តើម** ... ៣

**១-ស្ថានភាពស្ថាបនូបនីយកម្មសេដ្ឋកិច្ចឌីជីថលកម្ពុជា** ... ៤

១.១-ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ចនិងសង្គមឌីជីថល ... ៤

១.២-គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល ... ៥

១.៣-អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល ... ៦

១.៤-ក្រុមការងារបច្ចេកទេសសេដ្ឋកិច្ចឌីជីថល ... ៦

១.៥-យន្តការស្ថាបនូបនីយកម្មផ្សេងទៀត ... ៧

**២-ទិសដៅយុទ្ធសាស្ត្រអភិវឌ្ឍស្ថាប័នសេដ្ឋកិច្ចឌីជីថលកម្ពុជា** ... ៨

២.១-ទិសដៅយុទ្ធសាស្ត្រទី១ "រៀបចំនិងធ្វើសុវុឌ្ឍិកម្មផែនការអភិវឌ្ឍស្ថាប័ន" ... ៨

២.២-ទិសដៅយុទ្ធសាស្ត្រទី២ "ស្រាវជ្រាវ អភិវឌ្ឍ និងនវានុវត្តស្ថាប័ន" ... ៨

២.៣-ទិសដៅយុទ្ធសាស្ត្រទី៣ "អភិវឌ្ឍសមត្ថភាពនិងគុណវុឌ្ឍិស្ថាប័នជាប្រចាំ" ... ៨

២.៤-ទិសដៅយុទ្ធសាស្ត្រទី៤ "រៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តសេដ្ឋកិច្ចឌីជីថល" ... ៩

២.៥-ទិសដៅយុទ្ធសាស្ត្រទី៥ "ធ្វើវិសោធនកម្មច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន" ... ៩

២.៦-ទិសដៅយុទ្ធសាស្ត្រទី៦"ធ្វើសុខដុមនីយកម្មមុខងារស្ថាប័នសេដ្ឋកិច្ចឌីជីថល" ... ៩

**សេចក្តីសន្និដ្ឋាន** ... ៩

**សទ្ទានុក្រម** ... ១១

**ឯកសារយោង** ... ១៥

# សេចក្ដីផ្ដើម

សេដ្ឋកិច្ចឌីជីថលកម្ពុជា គឺជាម៉ូដែលថ្មីនៃកំណើនសេដ្ឋកិច្ចទីផ្សារ។ សេដ្ឋកិច្ចឌីជីថលកម្ពុជា ត្រូវបានធ្វើស្ថាបនូបនីយកម្មជាបន្តបន្ទាប់ ក្នុងកម្រិតជាតិ, រាជរដ្ឋាភិបាលទាំងមូល និងកម្រិតក្រសួង-ស្ថាប័នថ្នាក់កណ្ដាល ដោយផ្អែកលើអភិក្រម "អភិបាលកិច្ចក្នុងយុគសម័យឌីជីថល" ជំនួសឱ្យនវាភិបាលកិច្ចសាធារណៈឬការគ្រប់គ្រងសាធារណៈបែបថ្មីនិងអភិបាលកិច្ចសាធារណៈបែបប្រពៃណី អនុលោមតាមបទពិសោធ, ឧត្តមានុវត្តន៍ និងនិន្នាការស្ថាបនូបនីយកម្មសេដ្ឋកិច្ចឌីជីថលក្នុងបរិការណ៍តំបន់និងសកល ដែលមានសមានគតិភាពជាមួយនឹងបរិការណ៍កម្ពុជា ដើម្បីកសាងមូលដ្ឋានឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យកម្ពុជារយៈពេលវែង ប្រកបដោយមោទនភាពជាតិនិងភាពដ៏រស់រវើកនៃការកសាងជាតិ។

ស្ថាបនូបនីយកម្ម គឺជាការរៀបចំឱ្យក្លាយទៅជាស្ថាប័ន។ នៅក្នុងទីនេះ ស្ថាបនូបនីយកម្មសេដ្ឋកិច្ចឌីជីថលកម្ពុជា សំដៅដល់ការរៀបចំសេដ្ឋកិច្ចឌីជីថលកម្ពុជាឱ្យក្លាយទៅជាស្ថាប័ន ដែលចាប់ផ្ដើមពីក្របខណ្ឌគោលនយោបាយនិងផ្ដល់នូវលក្ខន្តិកៈគតិយុត្តដោយលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ ក្នុងបេសកកម្មនៃការបម្រើសេវាសាធារណៈសេដ្ឋកិច្ចឌីជីថលឬផលប្រយោជន៍ទូទៅផ្នែកសេដ្ឋកិច្ចឌីជីថល។ បច្ចុប្បន្ន ស្ថាប័នទាំងនោះរួមមានស្ថាប័នដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍ, ស្ថាប័នដឹកនាំសម្របសម្រួលនិងជំរុញ និងស្ថាប័នចូលរួមគាំទ្រ។ ស្ថាប័នដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល សំដៅដល់អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថលនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ក.ស.ហ.វ.), ស្ថាប័នដឹកនាំសម្របសម្រួលនិងជំរុញការកសាងនិងការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល សំដៅដល់គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល ដែលមានអគ្គលេខាធិការ-ដ្ឋានមួយជាសេនាធិការ និងស្ថាប័នចូលរួមគាំទ្រ សំដៅដល់ក្រសួង-ស្ថាប័ននិងអង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធនឹងសេដ្ឋកិច្ចឌីជីថល ដែលចូលរួមគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលក្នុងសមត្ថកិច្ចរបស់ខ្លួន។ ក្នុងបរិការណ៍តំបន់និងសកល ប្រទេសជាច្រើនបានបង្កើតស្ថាប័នសេដ្ឋកិច្ចឌីជីថលផងដែរ ដែលមានពហុលក្ខន្តិកៈគតិយុត្តអាស្រ័យលើប្រទេសនីមួយៗជាអាទិ៍ជាក្រសួង, ក្រុមប្រឹក្សា, គណៈកម្មាធិការ, អគ្គនាយកដ្ឋាន, នាយកដ្ឋាន, ទីភ្នាក់ងារ, អង្គភាព និង/ឬក្រុមការងារមានសមត្ថកិច្ចពាក់ព័ន្ធដែលរួមចំណែកជំរុញសម្ទុះនៃការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល។

ទស្សនាទាននេះគ្របដណ្ដប់លើក្របខណ្ឌគោលនយោបាយនិងក្របខណ្ឌគតិយុត្តកម្ពុជា ដែលជាមូលដ្ឋាននៃអត្ថិភាពស្ថាបនូបនីយកម្មសេដ្ឋកិច្ចឌីជីថលកម្ពុជា។ ក្របខណ្ឌគោលនយោបាយរួមបញ្ចូលនូវជាអាទិ៍សេចក្ដីព្រាងចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០, យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១, ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា២០២១-២០៣៥, គោលនយោបាយរដ្ឋាភិបាលឌីជីថល ២០២២-២០៣៥, ចក្ខុវិស័យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឆ្នាំ២០៣០ និងគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨។ រីឯ ក្របខណ្ឌគតិយុត្តរួមបញ្ចូលនូវច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានពាក់ព័ន្ធផ្ទាល់និងមិនផ្ទាល់នឹងសេដ្ឋកិច្ចឌីជីថល ប៉ុន្តែមានកម្មវិបាកឬបច្ច័យគតិយុត្តតិចឬច្រើនលើការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីសេដ្ឋកិច្ចឌីជីថល។

ក្នុងទស្សនាទាននេះ ការសិក្សាអំពីស្ថានភាពស្ថាបនូបនីយកម្មសេដ្ឋកិច្ចឌីជីថលកម្ពុជាបច្ចុប្បន្នមានសារៈសំខាន់ណាស់ព្រោះហេតុជាបុរេលក្ខខណ្ឌចាំបាច់សម្រាប់ការស្វែងយល់និងការស្វែងដឹងមុននឹងមានការស្នើឡើងនូវទិសដៅយុទ្ធសាស្ត្រអភិវឌ្ឍស្ថាប័នសេដ្ឋកិច្ចឌីជីថលកម្ពុជាសម្រាប់ជាគតិពិចារណា។

# ១-ស្ថានភាពស្ថាបនូបនីយកម្មសេដ្ឋកិច្ចឌីជីថលកម្ពុជា

តាំងពីឆ្នាំ២០២១ សេដ្ឋកិច្ចឌីជីថលកម្ពុជាត្រូវបានធ្វើស្ថាបនូបនីយកម្ម ដើម្បីឆ្លើយតបទៅនឹងទិសដៅ និងវិធានការគោលនយោបាយនៃក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា២០២១-២០៣៥ ដែលត្រូវបានរៀបចំដោយផ្អែកលើរបៀបវារៈគោលនយោបាយនៃយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤។ រហូតមកដល់បច្ចុប្បន្ន យន្តការស្ថាបនូបនីយកម្មសេដ្ឋកិច្ចឌីជីថលកម្ពុជា ស្ថិតនៅក្នុងដំណាក់កាលប្រែប្រួលថ្មីនៃការកសាងជាតិ ដែលក្នុងនោះប្រព័ន្ធអេកូឡូស៊ីស្ថាប័នត្រូវបានអភិវឌ្ឍគួរឱ្យកត់សម្គាល់។

## ១.១-ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ចនិងសង្គមឌីជីថល

នៅឆ្នាំ២០២១ ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ចនិងសង្គមឌីជីថល (ក.ស.ឌ.) ត្រូវបានបង្កើតដោយព្រះរាជក្រឹត្យ ដើម្បីជាសេនាធិការរបស់រាជរដ្ឋាភិបាលនៅក្នុងការដឹកនាំសម្របសម្រួលនិងការជំរុញការកសាងនិងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថលរស់រវើក តាមរយៈការរៀបចំមូលដ្ឋានគ្រឹះជំរុញការទទួលយកនិងបរិវត្តកម្មឌីជីថលនៅក្នុងគ្រប់តួអង្គសង្គម ទាំងរដ្ឋ ទាំងពលរដ្ឋ និងទាំងធុរជន ដើម្បីជំរុញសម្ទុះកំណើនសេដ្ឋកិច្ចថ្មីនិងលើកកម្ពស់សុខុមាលភាពសង្គម។ ក.ស.ឌ. មានសមាសភាពដូចតទៅ៖ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាជាប្រធាន, ឧបនាយករដ្ឋមន្ត្រី១រូបជាអនុប្រធានប្រចាំការ, រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ, រដ្ឋមន្ត្រីក្រសួងការពារជាតិ, រដ្ឋមន្ត្រី ក.ស.ហ.វ., រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ជាអនុប្រធាន ព្រមទាំងរដ្ឋមន្ត្រីក្រសួងនិងតំណាងស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាលជាសមាជិក។ ក.ស.ឌ. អាចមានសមាសភាពបន្ថែមជាប្រធានស្ថាប័នឬតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀតនៃរាជរដ្ឋាភិបាល តាមការចាំបាច់។ សមាសភាពជាក់ស្តែងនៃ ក.ស.ឌ. ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។ ក.ស.ឌ. មានគណៈកម្មាធិការជំនាញចំនួន៣ជាសេនាធិការលើការងារបច្ចេកទេស គឺគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល, គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល និងគណៈកម្មាធិការសន្តិសុខឌីជីថល។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការនីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យ។ ក.ស.ឌ. ត្រូវមានរូបសញ្ញានិងត្រាដោយឡែករបស់ខ្លួន ដែលត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន ក.ស.ឌ. សម្រាប់បំពេញតួនាទីនិងភារកិច្ចរបស់ខ្លួន។ គណៈកម្មាធិការនីមួយៗ មានសិទ្ធិប្រើប្រាស់ត្រាដោយឡែក ដែលត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន ក.ស.ឌ. សម្រាប់បំពេញតួនាទីនិងភារកិច្ចរបស់ខ្លួន។ ក.ស.ឌ. មានក្រុមប្រឹក្សាយោបល់បច្ចេកវិទ្យាឌីជីថលមួយ ដែលបំពេញ មុខងារសម្រាប់ពិគ្រោះនិងផ្តល់យោបល់កម្រិតគោលនយោបាយ សំដៅផ្តល់ធាតុចូលនិងជួយភ្ជាប់ទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការពាក់ព័ន្ធផ្សេងៗ។ ក្រុមប្រឹក្សាយោបល់បច្ចេកវិទ្យាឌីជីថល មានសមាសភាពចម្រុះមកពីដៃគូអភិវឌ្ឍ, ស្ថាប័នស្រាវជ្រាវ, ស្ថាប័នអប់រំ, វិស័យឯកជន និងតួអង្គពាក់ព័ន្ធសំខាន់ៗផ្សេងទៀតតាមការចាំបាច់។ សមាសភាពជាក់ស្តែង ព្រមទាំងតួនាទីនិងភារកិច្ចរបស់ក្រុមប្រឹក្សាយោបល់បច្ចេកវិទ្យាឌីជីថល ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន ក.ស.ឌ.។ ក.ស.ឌ. មានអគ្គលេខាធិការដ្ឋានមួយ ដែលបំពេញ មុខងារជាសេនាធិការនៅក្នុងការធានាការប្រព្រឹត្តទៅនៃការងាររដ្ឋបាល, ការសម្របសម្រួល, ការបូកសរុបរបាយការណ៍ និងការរៀបចំកិច្ចប្រជុំរបស់ ក.ស.ឌ.។ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវបំពេញមុខងារជាអគ្គលេខាធិការដ្ឋាននៃ ក.ស.ឌ.។ ក.ស.ឌ. អាចបង្កើតគណៈកម្មការឬក្រុមការងារផ្សេងៗដោយសេចក្តីសម្រេចរបស់ប្រធាន ក.ស.ឌ. តាមការចាំបាច់។




## ១.២-គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល

នៅឆ្នាំ២០២១ គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល (គ.ស.ធ.ឌ.) ត្រូវបានបង្កើតដោយអនុក្រឹត្យដើម្បីធានាប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពនៃការបំពេញមុខងារជាសេនាធិការលើការងារបច្ចេកទេសជូន ក.ស.ឌ. នៅក្នុងការដឹកនាំសម្របសម្រួលនិងការជំរុញការកសាងនិងការអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថលកម្ពុជា។ គ.ស.ធ.ឌ. មានសមាសភាពដូចតទៅ៖ រដ្ឋមន្ត្រី ក.ស.ហ.វ. ជាប្រធាន, រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍, រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម, រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងរដ្ឋលេខាធិការ ក.ស.ហ.វ. ១រូប ជាអនុប្រធាន, រដ្ឋលេខាធិការ១រូបមកពីក្រសួងពាក់ព័ន្ធនីមួយៗ និងតំណាងស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ជាសមាជិក ព្រមទាំងអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន គ.ស.ធ.ឌ. ជា សមាជិកអចិន្ត្រៃយ៍។ គ.ស.ធ.ឌ. អាចមានសមាសភាពបន្ថែមជាប្រធានស្ថាប័នឬតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀតនៃរាជរដ្ឋាភិបាល តាមការចាំបាច់។ សមាសភាពជាក់ស្តែងនៃ គ.ស.ធ.ឌ. ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។ គ.ស.ឌ.ធ. មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ។ អគ្គលេខាធិការដ្ឋាន គ.ស.ធ.ឌ. មានរចនាសម្ព័ន្ធជានាយកដ្ឋានចំនួន៤ គឺនាយកដ្ឋានរដ្ឋបាល ហិរញ្ញវត្ថុ និងធនធានមនុស្ស, នាយកដ្ឋានស្រាវជ្រាវគោលនយោបាយ និងច្បាប់, នាយកដ្ឋានគម្រោង នវានុវត្តន៍ និងកម្មវិធីអភិវឌ្ឍ, នាយកដ្ឋានបណ្តុះបណ្តាល ផ្សព្វផ្សាយ និងសហប្រតិបត្តិការ ព្រមទាំងនាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។ នាយកដ្ឋាននីមួយៗនៃអគ្គលេខាធិការដ្ឋាន គ.ស.ធ.ឌ. មានការិយាល័យចំណុះមួយចំនួនតាមការចាំបាច់។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះឱ្យនាយកដ្ឋាននីមួយៗនៃអគ្គលេខាធិការដ្ឋាន គ.ស.ធ.ឌ. ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក.ស.ហ.វ. និងជាប្រធាន គ.ស.ធ.ឌ.។ បច្ចុប្បន្ន នាយកដ្ឋាននីមួយៗនៃអគ្គលេខាធិការដ្ឋាន គ.ស.ធ.ឌ. មានការិយាល័យចំណុះចំនួន២។ គ.ស.ធ.ឌ. មានសិទ្ធិប្រើប្រាស់ត្រាដោយឡែក ដែលត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន ក.ស.ឌ. សម្រាប់បំពេញតួនាទីនិងភារកិច្ចរបស់ខ្លួន។




## ១.៣-អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល

នៅឆ្នាំ២០២៣ អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថលត្រូវបានបង្កើតនិងបំពេញបន្ថែមដោយអនុក្រឹត្យឱ្យស្ថិតនៅក្រោមឱវាទ ក.ស.ហ.វ. ដើម្បីធានាប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពនៃការដឹកនាំ ការគ្រប់គ្រង និងការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលកម្ពុជា។ អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល មាននាយកដ្ឋានក្រោមឱវាទចំនួន៣ គឺនាយកដ្ឋានកិច្ចការទូទៅ, នាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចឌីជីថល និងនាយកដ្ឋានកម្មវិធីសេដ្ឋកិច្ចឌីជីថល។ នាយកដ្ឋាននីមួយៗនៃអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល មានការិយាល័យក្រោមឱវាទមួយចំនួនតាមការចាំបាច់។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យក្រោមឱវាទនាយកដ្ឋាននីមួយៗនៃអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក.ស.ហ.វ.។




## ១.៤-ក្រុមការងារបច្ចេកទេសសេដ្ឋកិច្ចឌីជីថល

នៅឆ្នាំ២០២៣ ក្រុមការងារបច្ចេកទេសចំនួន១៣ ត្រូវបានបង្កើតដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល

ដើម្បីជំរុញនិងគាំទ្រសេដ្ឋកិច្ចឌីជីថលនិងរៀបចំកិច្ចព្រមព្រៀងសេដ្ឋកិច្ចឌីជីថល។ ក្រុមការងារបច្ចេកទេសទាំងនោះ គឺក្រុមការងារបច្ចេកទេសទទួលបន្ទុកការសម្របសម្រួលកណ្ដាល ដែលមានអគ្គលេខាធិការដ្ឋាន គ.ស.ធ.ឌ. ជាលេខាធិការដ្ឋាន, ក្រុមការងារបច្ចេកទេសទទួលបន្ទុកប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិក ដែលត្រូវដឹកនាំដោយ ក.ស.ហ.វ., ក្រុមការងារបច្ចេកទេសទទួលបន្ទុកសារពើពន្ធឌីជីថល ដែលត្រូវដឹកនាំដោយ ក.ស.ហ.វ., ក្រុមការងារបច្ចេកទេសទទួលបន្ទុកបច្ចេកវិទ្យាហិរញ្ញវត្ថុនិងនិយ័តកម្មធុរកិច្ចឌីជីថល ដែលត្រូវដឹកនាំដោយ ក.ស.ហ.វ., ក្រុមការងារបច្ចេកទេសទទួលបន្ទុកការសម្រួលពាណិជ្ជកម្មឌីជីថល ដែលត្រូវដឹកនាំដោយ ក.ស.ហ.វ., ក្រុមការងារបច្ចេកទេសទទួលបន្ទុកការទូទាត់សងប្រាក់តាមប្រព័ន្ធឌីជីថល ដែលត្រូវដឹកនាំដោយធនាគារជាតិនៃកម្ពុជា, ក្រុមការងារបច្ចេកទេសទទួលបន្ទុកពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលត្រូវដឹកនាំដោយក្រសួងពាណិជ្ជកម្ម, ក្រុមការងារបច្ចេកទេសទទួលបន្ទុកអត្តសញ្ញាណឌីជីថល ដែលត្រូវដឹកនាំដោយក្រសួងមហាផ្ទៃ, ក្រុមការងារបច្ចេកទេសទទួលបន្ទុករំហូរកម្លាំងពលកម្មជំនាញនិងការបណ្ដុះបណ្ដាលជំនាញឌីជីថល ដែលត្រូវដឹកនាំដោយក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ, ក្រុមការងារបច្ចេកទេសទទួលបន្ទុកការកសាងធនធានមនុស្សឌីជីថល ដែលត្រូវដឹកនាំដោយក្រសួងអប់រំ យុវជន និងកីឡា, ក្រុមការងារបច្ចេកទេសទទួលបន្ទុកការលើកកម្ពស់និងការជំរុញបច្ចេកវិទ្យា វិទ្យាសាស្ត្រ និងនវានុវត្តន៍ ដែលត្រូវដឹកនាំដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ក្រុមការងារបច្ចេកទេសទទួលបន្ទុកសុវត្ថិភាពឌីជីថល សន្តិសុខសាយប័រ និងអភិបាលកិច្ចទិន្នន័យ ដែលត្រូវដឹកនាំដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រុមការងារបច្ចេកទេសទទួលបន្ទុកហេដ្ឋារចនាសម្ព័ន្ធនិងការតភ្ជាប់ឌីជីថល ដែលត្រូវដឹកនាំដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។ ក្រុមការងារបច្ចេកទេសនីមួយៗមានភារកិច្ចផ្ដល់កិច្ចសហការជាមួយគ្នាក្នុងការជំរុញការងារដែលមានលក្ខណៈអន្តរវិស័យ ដោយមានការសម្របសម្រួលពីក្រុមការងារបច្ចេកទេសទទួលបន្ទុកការសម្របសម្រួលកណ្ដាល ក៏ដូចជារៀបចំ បូកសរុប និងផ្ដល់របាយការណ៍វឌ្ឍនភាពការងារ សមិទ្ធកម្ម និងបញ្ហាប្រឈមជូនក្រុមការងារបច្ចេកទេសទទួលបន្ទុកការសម្របសម្រួលកណ្ដាល។ សមាសភាពជាក់ស្ដែងនៃក្រុមការងារបច្ចេកទេសនីមួយៗ ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល។

### ១.៥-យន្តការស្ថាបនូបនីយកម្មផ្សេងទៀត

ក្រៅពីយន្តការស្ថាបនូបនីយកម្មដូចបានរៀបរាប់ខាងលើ, កម្ពុជាមានយន្តការស្ថាបនូបនីយកម្មផ្សេងទៀតដែលជួយគាំទ្រជាទូទៅដល់ការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីសេដ្ឋកិច្ចឌីជីថល។ ក្នុងនោះ ធនាគារជាតិនៃកម្ពុជា ជាធនាគារកណ្ដាលដែលទទួលបន្ទុកអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យធនាគារ, អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.) ដែលមានមជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុនិងនិយ័តករក្រោមឱវាទចំនួន៦ ជាសេនាធិការទទួលបន្ទុកអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ និងក្រសួង-ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ដែលចូលរួមជំរុញនិងគាំទ្រដល់ការកសាងនិងការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលកម្ពុជា ដែលរួមមានជាអាទិ៍នាយកដ្ឋានវិស័យសេដ្ឋកិច្ចថ្មីនៃអគ្គនាយកដ្ឋានគោលនយោបាយនៃ ក.ស.ហ.វ. ដែលទទួលបន្ទុកការងារគោលនយោបាយវិស័យសេដ្ឋកិច្ចថ្មី (ដែលមានការិយាល័យក្រោមឱវាទចំនួន៦ គឺការិយាល័យវិភាគជាយុទ្ធសាស្ត្រទស្សនវិស័យអនាគត, ការិយាល័យគោលនយោបាយសេដ្ឋកិច្ចបៃតង, ការិយាល័យគោលនយោបាយសេដ្ឋកិច្ចឌីជីថល, ការិយាល័យគោលនយោបាយលើកទឹកចិត្តវិនិយោគ និងការិយាល័យកិច្ចការទូទៅនិងសម្របសម្រួល), អគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋនិងឯកជន ដែលមានសមត្ថកិច្ចដឹកនាំនិងគ្រប់គ្រងយន្តការ

ភាពជាដៃគូរវាងរដ្ឋនិងឯកជន ក្នុងការគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល, ការិយាល័យនីតិសេដ្ឋកិច្ចឌីជីថល នៃផ្នែកនីតិកម្មចំណាយនៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្មនៃ ក.ស.ហ.វ. ដែលជួយគាំទ្រផ្នែកនីតិកម្ម សេដ្ឋកិច្ចឌីជីថល, មជ្ឈមណ្ឌលបណ្ដុះធុរកិច្ចថ្មីតេជោ ដែលជាគ្រឹះស្ថានសាធារណរដ្ឋបាល ទទួលបន្ទុកបណ្ដុះ ធុរកិច្ចថ្មីសេដ្ឋកិច្ចឌីជីថល និងក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀតនៃរាជរដ្ឋាភិបាល ដែលជួយគាំទ្រដល់ការជំរុញ បរិវត្តកម្មសេដ្ឋកិច្ចឌីជីថល ជាពិសេសពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធឌីជីថល, សន្តិសុខឌីជីថល, រដ្ឋាភិបាល ឌីជីថល, ការការពារអ្នកប្រើប្រាស់, ការប្រកួតប្រជែងដោយស្មើភាពនិងស្មោះត្រង់ឬសុចរិត, ការការពារទិន្នន័យ បុគ្គល, ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនិងធុរកិច្ចឌីជីថល, ការការពារកម្មសិទ្ធិបញ្ញា, ការប្រឆាំងការសម្អាត ប្រាក់និងហិរញ្ញប្បទានភេរវកម្មនិងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ និងសារពើពន្ធ សេដ្ឋកិច្ចឌីជីថល។

## ២-ទិសដៅយុទ្ធសាស្ត្រអភិវឌ្ឍស្ថាប័នសេដ្ឋកិច្ចឌីជីថលកម្ពុជា

ទិសដៅយុទ្ធសាស្ត្រអភិវឌ្ឍស្ថាប័នសេដ្ឋកិច្ចឌីជីថលកម្ពុជា ដែលត្រូវស្នើឡើងដើម្បីឆ្លើយតបទៅនឹង បញ្ហាប្រឈមមួយចំនួនដែលកម្ពុជាបាននិងកំពុងជួបប្រទះ ផ្ដោតសំខាន់លើ ការរៀបចំនិងការធ្វើសុវត្ថិកម្មផែនការ អភិវឌ្ឍស្ថាប័ន, ការស្រាវជ្រាវ ការអភិវឌ្ឍ និងនវានុវត្តន៍ស្ថាប័ន, ការអភិវឌ្ឍសមត្ថភាពនិងគុណវុឌ្ឍិស្ថាប័នជាប្រចាំ, ការរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តសេដ្ឋកិច្ចឌីជីថល, ការធ្វើវិសោធនកម្មច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ជាធរមាន និងការធ្វើសុខដុមនីយកម្មមុខងារស្ថាប័នសេដ្ឋកិច្ចឌីជីថល។

### ២.១-ទិសដៅយុទ្ធសាស្ត្រទី១ "រៀបចំនិងធ្វើសុវត្ថិកម្មផែនការអភិវឌ្ឍស្ថាប័ន"

ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនឹងសេដ្ឋកិច្ចឌីជីថល ត្រូវរៀបចំនិងធ្វើសុវត្ថិកម្មផែនការអភិវឌ្ឍស្ថាប័ន របស់ខ្លួនសម្រាប់រយៈពេលវែងរហូតដល់ឆ្នាំ២០៣០ ដោយកំណត់អំពីចក្ខុវិស័យ, គោលបំណង, គោលដៅ, អភិក្រម, គោលការណ៍, ផែនការសកម្មភាព និងយន្តការអនុវត្ត, សម្រួបសម្រួល, តាមដាន និងវាយតម្លៃឱ្យ បានច្បាស់លាស់និងជាក់លាក់ សម្រាប់ជាមគ្គុទេសក៍អភិវឌ្ឍស្ថាប័ននៃឧត្តមភាព។

### ២.២-ទិសដៅយុទ្ធសាស្ត្រទី២ "ស្រាវជ្រាវ អភិវឌ្ឍ និងនវានុវត្តស្ថាប័ន"

ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនឹងសេដ្ឋកិច្ចឌីជីថលត្រូវជំរុញនិងលើកកម្ពស់ការស្រាវជ្រាវ ការអភិវឌ្ឍ និងនវានុវត្តន៍ស្ថាប័ន ផ្អែកលើបទពិសោធ, ឧត្តមានុវត្តន៍ និងនិន្នាការអន្តរជាតិ ដែលមានសមានគតិភាពជាមួយ នឹងបរិការណ៍កម្ពុជា ដោយប្រកាន់ខ្ជាប់នូវអភិក្រម "ការចាប់យក, ការកែសម្រប និងការធ្វើនវានុវត្តន៍បន្ថែម"។ ការស្រាវជ្រាវជាហេតុបច្ច័យនៃការអភិវឌ្ឍនិងនវានុវត្តន៍ស្ថាប័ន។

### ២.៣-ទិសដៅយុទ្ធសាស្ត្រទី៣ "អភិវឌ្ឍសមត្ថភាពនិងគុណវុឌ្ឍិស្ថាប័នជាប្រចាំ"

ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនឹងសេដ្ឋកិច្ចឌីជីថលត្រូវអភិវឌ្ឍសមត្ថភាពនិងគុណវុឌ្ឍិស្ថាប័នជាប្រចាំ ដើម្បីឱ្យមានមូលធនមនុស្សឬភាពជាអ្នកដឹកនាំសេដ្ឋកិច្ចឌីជីថល សំដៅធានាបាននូវប្រសិទ្ធភាពនិងសក្តិសិទ្ធិភាព នៃការបំពេញមុខងារ, តួនាទី និងភារកិច្ច អនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដោយ ប្រកាន់ខ្ជាប់នូវស្មារតីនៃការសិក្សារៀនសូត្រជាប្រចាំ តាមរយៈជាអាទិ៍ការធ្វើទស្សនកិច្ចសិក្សា, ការចូលរួមក្នុង សិក្ខាសាលា, វគ្គសិក្សា និងកម្មវិធីបណ្ដុះបណ្ដាលនានា ក្នុងការចូលរួមវិភាគទានសម្រេចបាននូវចក្ខុវិស័យ គោលនយោបាយរបស់រាជរដ្ឋាភិបាល ដូចមានកំណត់ក្នុងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថល កម្ពុជា២០២១-២០៣៥, បញ្ចកោណទី៥ "ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល" នៃយុទ្ធសាស្ត្របញ្ចកោណ-

ដំណាក់កាលទី១ និងគោលនយោបាយ, យុទ្ធសាស្ត្រ, ផែនការអភិវឌ្ឍ និងផែនទីមគ្គុទេសក៍។

### ២.៤-ទិសដៅយុទ្ធសាស្ត្រទី៤ "រៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តសេដ្ឋកិច្ចឌីជីថល"

ស្ថាប័នមាន សមត្ថកិច្ចពាក់ព័ន្ធនឹងសេដ្ឋកិច្ចឌីជីថល ត្រូវចូលរួមសហការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីសេដ្ឋកិច្ចឌីជីថលនិងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនិងដាក់សេដ្ឋកិច្ចឌីជីថលទៅក្នុងអនុវិស័យនៃប្រព័ន្ធគណនីជាតិ ដូចមានកំណត់ក្នុងអាទិភាពទី៨នៃមុំទី២ "ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល, ធុរកិច្ចឌីជីថល, ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងប្រព័ន្ធនវានុវត្តន៍ឌីជីថល" នៃបញ្ចកោណទី៥ "ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល" យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១។ ក្នុងនោះ សេចក្តីព្រាងច្បាប់ស្តីពីសេដ្ឋកិច្ចឌីជីថល ត្រូវកំណត់អំពីយន្តការស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនឹងសេដ្ឋកិច្ចឌីជីថល ដែលអាចមានស្ថាប័ន ដឹកនាំគ្រប់គ្រង និងអភិវឌ្ឍ, ស្ថាប័នដឹកនាំសម្របសម្រួលនិងជំរុញ និងស្ថាប័នចូលរួមគាំទ្រ បន្ថែមទៅលើវិធានសារវន្តពាក់ព័ន្ធផ្សេងទៀត។

### ២.៥-ទិសដៅយុទ្ធសាស្ត្រទី៥ "ធ្វើវិសោធនកម្មច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន"

ច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានមួយចំនួន ដែលអាចមានកម្មវិបាកឬបច្ច័យគតិយុត្តឬនិយ័តកម្មធ្វើឱ្យរាំងស្ទះដល់ការអភិវឌ្ឍស្ថាប័ន ក៏អាចជាកម្មវត្ថុនៃការធ្វើវិសោធនកម្មតាមការចាំបាច់ផងដែរ។ ការធ្វើវិសោធនកម្មច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ប្រកបដោយសនិទានភាពឬវិចារណភាព បើកផ្លូវដល់ការធ្វើវិសិដ្ឋកម្មស្ថាប័នដែលមានលក្ខណៈអំណោយផលដល់ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលកម្ពុជាដ៏រស់រវើក។

### ២.៦-ទិសដៅយុទ្ធសាស្ត្រទី៦ "ធ្វើសុខដុមនីយកម្មមុខងារស្ថាប័នសេដ្ឋកិច្ចឌីជីថល"

សេដ្ឋកិច្ចឌីជីថលគឺជាម៉ូដែលថ្មីនៃកំណើន ដែលមានលក្ខណៈអន្តរវិស័យ។ ក្នុងន័យនេះ ការអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រសេដ្ឋកិច្ចឌីជីថល ប្រកបដោយជោគជ័យ មិនអាចខ្វះការធ្វើសុខដុមនីយកម្មមុខងារស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនឹងសេដ្ឋកិច្ចឌីជីថលឡើយ។ ហេតុនេះ ស្មារតីនៃការធ្វើសុខដុមនីយកម្មនេះត្រូវឆ្លុះបញ្ចាំងឱ្យឃើញមិនត្រឹមតែក្នុងគោលនយោបាយនិងយុទ្ធសាស្ត្រទេ ប៉ុន្តែត្រូវឆ្លុះបញ្ចាំងឱ្យឃើញផងដែរនៅក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីជាប្រទីបបំភ្លឺផ្លូវដល់ការបំពេញមុខងារស្ថាប័នជាក់ស្តែង។ ក្នុងស្មារតីនេះ ស្ថាប័នមាន សមត្ថកិច្ចពាក់ព័ន្ធនឹងសេដ្ឋកិច្ចឌីជីថលត្រូវបំពេញមុខងាររបស់ខ្លួន ដោយសហការគ្នាជាធ្លុងមួយ, មានការសម្របសម្រួល និងការពង្រឹងកិច្ចសហការនិងកិច្ចសហប្រតិបត្តិការអន្តរស្ថាប័ន ប្រកបដោយស្មារតីអន្តរសកម្មបំផុត, សហថាមពល, សហនវានុវត្តន៍, សហការទទួលខុសត្រូវខ្ពស់ និងសិនិទ្ធភាព អនុលោមតាមអភិក្រមរដ្ឋាភិបាលទាំងមូលនិងជវភាពនៃប្រព័ន្ធតួអង្គតែមួយ។

## សេចក្តីសន្និដ្ឋាន

យន្តការស្ថាបនូបនីយកម្មសេដ្ឋកិច្ចឌីជីថលកម្ពុជា ត្រូវបានរៀបចំដោយរដ្ឋយុទ្ធសាស្ត្រវិទូដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនិយមនិងប្រាកដនិយមរបស់កម្ពុជា ដូចមានកំណត់ក្នុងគោលនយោបាយនវសេរីនិយមឌីជីថលពាក់ព័ន្ធជាធរមាន ក្នុងការដឹកនាំ, ការគ្រប់គ្រង និងការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលកម្ពុជា ដែលជាម៉ូដែលថ្មីនៃកំណើនសេដ្ឋកិច្ចជាតិ និងជាមូលដ្ឋានឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០និងចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ក្នុងការកសាងជាតិ ប្រកបដោយមោទនភាពនិងភាពដ៏រស់រវើក។ ទោះបីជាយ៉ាងនេះក្តី យន្តការស្ថាបនូបនីយកម្មសេដ្ឋកិច្ចឌីជីថលកម្ពុជា អាចដំណើរការរលូនប្រកបដោយជវភាពនិងនវានុវត្តន៍ ទាមទារនូវ "ការកែទម្រង់និងការពង្រឹងអភិបាលកិច្ចស្ថាប័ន" ដែលជាស្នូលយុទ្ធសាស្ត្រនៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាល

ទី១។ នៅក្នុងទីនេះ ការកែទម្រង់និងការពង្រឹងអភិបាលកិច្ចស្ថាប័ន អាចឆ្លុះបញ្ចាំងឱ្យឃើញតាមរយៈការបន្តដាក់ចេញនិងការអនុវត្តនូវទិសដៅយុទ្ធសាស្ត្រអភិវឌ្ឍស្ថាប័នសេដ្ឋកិច្ចឌីជីថលកម្ពុជារបស់ក្រសួង-ស្ថាប័ន និងអង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ពាក់ព័ន្ធនឹងជាអាទិ៍ការរៀបចំនិងការធ្វើសុវត្ថិកម្មផែនការអភិវឌ្ឍស្ថាប័ន, ការស្រាវជ្រាវ ការអភិវឌ្ឍ និងនវានុវត្តន៍ស្ថាប័ន, ការអភិវឌ្ឍសមត្ថភាពនិងគុណវុឌ្ឍិស្ថាប័នជាប្រចាំ, ការរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តសេដ្ឋកិច្ចឌីជីថល ដោយរួមបញ្ចូលនូវឧត្តមគតិគតិយុត្តនៃការរៀបចំវត្តិករសាស្ត្រស្ថាប័នសេដ្ឋកិច្ចឌីជីថលកម្ពុជា, ការធ្វើវិសោធនកម្មច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន និងការធ្វើសុខដុមនីយកម្មមុខងារស្ថាប័នសេដ្ឋកិច្ចឌីជីថល សម្រាប់រយៈពេលខ្លី, មធ្យម និងវែង អនុលោមតាមអភិក្រមរដ្ឋាភិបាលទាំងមូល, ជវភាពនៃប្រព័ន្ធតួអង្គតែមួយ និងរដ្ឋកិច្ចសមេកភាព ព្រមទាំងឈរលើគោលគំនិត "ដើម្បីបម្រើជាតិនិងប្រជាជនជាធំ"។

## សន្ទានុក្រម

| ល.រ | ពាក្យគន្លឹះជាភាសាខ្មែរ | ពាក្យគន្លឹះជាភាសាអង់គ្លេស | ពាក្យគន្លឹះជាភាសាបារាំង |
|---|---|---|---|
| ១ | ការការពារកម្មសិទ្ធិបញ្ញា | Intellectual Property Protection | Protection de la Propriété Intellectuelle |
| ២ | ការការពារទិន្នន័យបុគ្គល | Personal Data Protection | Protection des Données Personnelles |
| ៣ | ការការពារអ្នកប្រើប្រាស់ | Consumer Protection | Protection du Consommateur |
| ៤ | ការកែទម្រង់ | Reform | Réforme |
| ៥ | ការកែសម្រប | Adaptation | Adaptation |
| ៦ | ការចាប់យក | Adoption | Adoption |
| ៧ | ការប្រកួតប្រជែង | Competition | Compétition |
| ៨ | ការប្រឆាំងការសម្អាតប្រាក់ | Anti-Money Laundering | Lutte contre le Blanchiment d'Argent |
| ៩ | ការប្រឆាំងហិរញ្ញប្បទានភេរវកម្ម | Combating financing of Terrorism | Lutte contre le Financement du Terrorisme |
| ១០ | ការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ | Combating the Financing of Proliferation of Weapons of Mass Destruction | Lutte contre le Financement des Armes de Destruction Massive |
| ១១ | គោលនយោបាយនវសេរីនិយមឌីជីថល | Digital Neoliberal Policy | Politique Néolibérale Numérique |
| ១២ | ឌីនាមិកនៃប្រព័ន្ធតួអង្គតែមួយ | Dynamics of stakeholders system | Dynamique du Système des Parties Prenantes |
| ១៣ | ធុរកិច្ចឌីជីថល | Digital Business | Affaire Numérique |

| | | | |
|---|---|---|---|
| ១៤ | ធុរកិច្ចថ្មី | Start-up | Jeune Pousse |
| ១៥ | ធុរកិច្ចថ្មីសេដ្ឋកិច្ចឌីជីថល | Digital Economy Start-up | Jeune Pousse de l'Economie Numérique |
| ១៦ | នវសេរីនិយម | Neoliberalism | Néolibéralisme |
| ១៧ | នវានុវត្តន៍ | Innovation | Innovation |
| ១៨ | នវានុវត្តន៍ស្ថាប័ន | Institutional Innovation | Innovation Institutionnel |
| ១៩ | នវាភិបាលកិច្ចសាធារណៈ/ ការគ្រប់គ្រងសាធារណៈបែបថ្មី | New Public Management ( NPM ) | Nouvelle Gestion Publique |
| ២០ | នីតិសេដ្ឋកិច្ចឌីជីថល | Digital Economy Law | Droit de l'Economie Numérique |
| ២១ | បច្ចេកវិទ្យាហិរញ្ញវត្ថុ | Financial Technology ( FinTech ) | Technologie Financière ( FinTech ) |
| ២២ | បរិវត្តកម្មសេដ្ឋកិច្ចឌីជីថល | Digital Economy Transformation | Transformation de l'Economie Numérique |
| ២៣ | ប្រព័ន្ធនវានុវត្តន៍ឌីជីថល | Digital Innovation System | Système d'innovation numérique |
| ២៤ | ប្រព័ន្ធអេកូឡូស៊ីសេដ្ឋកិច្ចឌីជីថល | Digital Economy Ecosystem | Ecosystème de l'Economie Numérique |
| ២៥ | ប្រព័ន្ធអេកូឡូស៊ីស្ថាប័ន | Institutional Ecosystem | Ecosystème Institutionnel |
| ២៦ | ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក | Electronic Commerce ( E-Commerce ) | Commerce Electronique |
| ២៧ | យុគសម័យឌីជីថល | Digital Era | Ere Numérique |
| ២៨ | រដ្ឋកិច្ចសមេកភាព | Unity Government | Gouvernement d'Unité |
| ២៩ | រដ្ឋយុទ្ធសាស្ត្រវិទូ | Strategic State | Etat-Stratège |
| ៣០ | រដ្ឋាភិបាលឌីជីថល | Digital Government | Government Numérique |

| | | | |
|---|---|---|---|
| ៣១ | លក្ខន្តិកៈគតិយុត្ត | Legal Status | Statut Juridique |
| ៣២ | វត្តិករសាស្ត្រ | Taxonomy | Taxonomie |
| ៣៣ | វត្តិករសាស្ត្រស្ថាប័ន | Institutional Taxonomy | Taxonomie Institutionnelle |
| ៣៤ | វិធានសារវន្ត | Fundamental Rules | Règles Fondamentales |
| ៣៥ | សនិទានភាព/វិចារណភាព | Rationality | Rationalité |
| ៣៦ | សន្តិសុខឌីជីថល | Digital Security | Sécurité Numérique |
| ៣៧ | សហការទទួលខុសត្រូវ | Co-responsibility | Co-responsabilité |
| ៣៨ | សហថាមពល/សហថាមភាព | Synergy | Synergie |
| ៣៩ | សហនវានុវត្តន៍ | Co-innovation | Co-innovation |
| ៤០ | សិនិទ្ធភាព | Cohesion/Cordiality | Cohésion/Cordialité |
| ៤១ | សុខដុមនីយកម្ម | Harmonization | Harmonisation |
| ៤២ | សុវឌ្ឍិកម្ម | Improvement | Amélioration |
| ៤៣ | សេដ្ឋកិច្ចថ្មី | New Economy | Nouvelle Economie |
| ៤៤ | សេដ្ឋកិច្ចឌីជីថល | Digital Economy | Economie Numérique |
| ៤៥ | សេដ្ឋកិច្ចទីផ្សារ | Market Economy | Economie de Marché |
| ៤៦ | សេដ្ឋកិច្ចបៃតង | Green Economy | Economie Verte |
| ៤៧ | ស្ថាប័ននៃឧត្តមភាព | Institution of Excellence | Institution d'Excellence |
| ៤៨ | ស្ថាបនូបនីយកម្ម | Institutionalization | Institutionnalisation |
| ៤៩ | ហេដ្ឋារចនាសម្ព័ន្ធឌីជីថល | Digital Infrastructure | Infrastructure Numérique |
| ៥០ | អន្តរសកម្ម | Interactive | Interactif |
| ៥១ | អន្តរស្ថាប័ន | Inter-institution | Inter-institution |
| ៥២ | អភិក្រមរដ្ឋាភិបាលទាំងមូល | Whole-of-Government Approach | Approche Pangouvernementale |

| | | | |
|---|---|---|---|
| ៥៣ | អភិបាលកិច្ចក្នុងយុគសម័យឌីជីថល | Digital Era Governance | Gouvernance à l'ère du Numérique |
| ៥៤ | អភិបាលកិច្ចស្ថាប័ន | Institutional Governance | Governance Institutionnelle |
| ៥៥ | ឧត្តមគតិគតិយុត្ត | Legal Ideology | Idéologie Juridique |

## ឯកសារយោង

- សេចក្តីព្រាងចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០
- យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១
- ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា២០២១-២០៣៥
- គោលនយោបាយរដ្ឋាភិបាលឌីជីថល២០២២-២០៣៥
- ចក្ខុវិស័យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឆ្នាំ២០៣០
- គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា២០២៣-២០២៨
- ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារឆ្នាំ២០២១
- ច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជនឆ្នាំ២០២១
- ព្រះរាជក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ចនិងសង្គមឌីជីថល ឆ្នាំ២០២១
- អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល ឆ្នាំ២០២២
- អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឆ្នាំ២០២២
- អនុក្រឹត្រស្តីពីការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថលឱ្យស្ថិតក្រោមឱវាទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឆ្នាំ២០២៣
- អនុក្រឹត្យស្តីពីការបង្កើតមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មីតេជោជាគ្រឹះស្ថានសាធារណរដ្ឋបាលឆ្នាំ២០២៣
- អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុ មិនមែនធនាគារឆ្នាំ២០២១
- ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋាននិងអង្គភាពក្រោមឱវាទរបស់អគ្គលេខាធិ-ការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារឆ្នាំ២០២១
- ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះឱ្យនាយកដ្ឋាននៃអគ្គលេខាធិការ-ដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថលឆ្នាំ២០២២
- ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋាន គោលនយោបាយនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឆ្នាំ២០២២
- ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃផ្នែកក្រោមឱវាទលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម ឆ្នាំ២០២១

អត្ថបទដោយ

* លោក **ខេន ចន្ថា** បរិញ្ញាបត្រជាន់ខ្ពស់នីតិកិច្ចសន្យាសាធារណៈនិងបរិញ្ញាបត្រជាន់ខ្ពស់សកម្មភាពសេដ្ឋកិច្ចនិងកិច្ចសហប្រតិបត្តិការសមូហភាពដែនដីនៅអឺរ៉ុបនៃសាកលវិទ្យាល័យលុយមីយែរលីយ៉ុង២នៃសាធារណរដ្ឋបារាំង។

** លោក **សូ សុភា** បរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យាព័ត៌មាននៃសាកលវិទ្យាល័យឡារ៉ូឆែលនៃសាធារណរដ្ឋបារាំង និងបរិញ្ញាបត្រជាន់ខ្ពស់នីតិភូមិបាលនិងនីតិបេតិកភណ្ឌនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ស្កេនដើម្បីចូលទៅកាន់ផតថលបច្ចេកវិទ្យាហិរញ្ញវត្ថុ នៃ អ.ស.ហ.

ស្កេនដើម្បីទាញយកកម្មវិធីសទ្ទានុក្រមបច្ចេកវិទ្យាហិរញ្ញវត្ថុ

@fintechportalfsa

©រក្សាសិទ្ធិដោយ មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាន អ.ស.ហ.
ខែធ្នូ ឆ្នាំ២០២៣